ព្រហ្មខរៈ

# វិភាគ វេយ្យាករណ៍ និង សម្ពន្ធមាលា

# ANALYSE GRAMMATICALE ET LOGIQUE

វិ. 61

៣

សំរាប់ថ្នាក់ទី ៤ និងទី ៣ ទំនើប

សំរាប់បេក្ខជនប្រឡងប្រកាសនីយបត្រ និងវិញ្ញាបនបត្រ

ន.ន.ថ្ងៃ ១០-៣-៦១
415
ព្រហ្ម

# សម្ពន្ធ

# វេយ្យាករណ៍

# និងសម្ពន្ធមាលា

រៀបរៀងដោយ

ព្រហ្មវីរៈ

សំរាប់ថ្នាក់ទី ៤ និងទី ៣ ទំនើប នៃវិទ្យាល័យ និង អនុវិទ្យាល័យ

សំរាប់ បេក្ខជនប្រឡងប្រកាសនិយប័ត្រ

នឹងវិញ្ញាបនបត្រមធ្យមសិក្សា

បោះពុម្ពលើកដំបូង

ការផ្សាយរបស់

បណ្ណាគារ

លេខ ៦៧ វិថីព្រះបាទចក្ខុភាដា ភ្នំពេញ

ព.ស. ២៥០២ គ.ស. ១៩៥៩

រក្សាសិទ្ធិ

# អារព្ភបទ

សៀវភៅក្បួនសម្ពន្ធនេះ ខ្ញុំបានរៀបរៀងឡើង ដើម្បីជួយសម្រាលកម្លាំងសាស្ត្រាចារ្យ និងសិស្សអ្នកសិក្សាវេយ្យាករណ៍ខ្មែរ ហើយជាពិសេសនោះ ដើម្បីជាជំនួយដល់បេក្ខជនអ្នកប្រឡងប្រកាសនីយប័ត្រ និងវិញ្ញាបនប័ត្រមធ្យមសិក្សា ដែលតម្រូវតាមកម្មវិធី ថ្នាក់ទី ៤ និងទី ៣ ទំនើប ។

សៀវភៅ សម្ពន្ធនេះ ចែកជាបីផ្នែកគឺ ៖

ក) បឋមសញ្ញាណ

ខ) សម្ពន្ធពាក្យ ឬ សម្ពន្ធវេយ្យាករណ៍

គ) សម្ពន្ធប្រយោគ ឬ សម្ពន្ធមាលា (សម្ពន្ធក្បួន)

ក្នុងផ្នែកនីមួយៗ មាន មេរៀន, របៀបសម្ពន្ធនិងការហាត់គ្រប់គ្រាន់ អាចនឹងរៀនខ្លួនឯងបានដោយងាយ ។

ក៏ពិតមែន, ក្បួនសម្ពន្ធនេះ មិនជាវិសេសវិសាលណាស់ណាទេ ព្រោះធ្វើឡើងទៅតាមក្បួនវេយ្យាករណ៍ដែលយកមកអនុវត្តសព្វថ្ងៃ ប៉ុន្តែជាក្បួនពិសេសមួយអាចជួយបំបាត់ការខ្វះខាតខ្លះក្នុងការសិក្សាអក្សរសាស្ត្រជាតិ ។

ភ្នំពេញថ្ងៃទី ២៦ ឧសភា ១៩៥៩

ព្រហ្មវីរៈ

# សេចក្ដីយល់ឃើញ

ខ្ញុំសប្បាយរីករាយក្នុងចិត្តជាបំផុត ដោយបានឃើញសៀវភៅ "សម្ពន្ធវេយ្យាករណ៍ និង មាលា" របស់លោកបានចេញផ្សាយរួចហើយ ។

ពិតមែនតែក្បួនខ្នាតនេះ នៅមិនទាន់បានពេញលេញវែងឆ្ងាយនៅឡើយ, តែខ្ញុំយល់ថាជាក្បួនមួយយ៉ាងពិសេសណាស់សំរាប់អ្នកសិក្សាក្នុងគ្រាបច្ចុប្បន្ននេះ ដែលកំពុងតែប៉ះពាល់ទៅលើការខ្វះខាតខាងសៀវភៅក្បួនខ្នាតផ្សេង ៗ ក្នុងការសិក្សាភាសាជាតិ ។

ខ្ញុំសូមថ្លែងសេចក្ដីសរសើរយ៉ាងស្មោះស្ម័គ្រ បំពោះរូបលោកដែលខិតខំព្យាយាមរៀបចំឲ្យកើតបានជារូបរាងសៀវភៅតម្រូវតាមសេចក្ដីត្រូវការក្នុងកាលៈទេសៈនេះឈ្មោះថា លោកជួយទ្រោលបំភ្លឺឲ្យយុវសិស្សជាតិយើងដើរទៅរកលក្ខណ៍គោលបំណេះវិជ្ជារបស់ជាតិខ្លួនបានយ៉ាងគួរស្រួលសមបំណង ។

ភ្នំពេញ ថ្ងៃ១៨ ឧសភា១៩៥៩

លី-ធាមតេង

# សម្ពន្ធ

## ក.– បឋមសញ្ញាណ – –

១– ពាក្យថា សម្ពន្ធ ជាពាក្យបាលីមកពី សំ ប្រែថា ព្រម, ជាមួយ ផ្សំនឹង ពន្ធ ប្រែថាចង បានសេចក្តីថា ចងជាមួយ គឺការចងបទជាសង្កាត់ផ្សេងៗ ដើម្បីពិនិត្យឲ្យដឹងថានៅក្នុងសង្កាត់នោះ បទណាចូលទៅរកបទណា, បទណាជាប្រធាន, ជាកិរិយា, ជាកម្ម តាមក្បួនវេយ្យាករណ៍ ។

ក្នុងភាសានីមួយៗ ទោះបីក្នុងការសរសេរ ឬនិយាយក្តី សុទ្ធតែចងក្រង សំដី ដោយពាក្យដែលបង្កើតបានជា វាក្យាង្គ ពាក្យនឹង វាក្យាង្គ ទាំងឡាយនោះបង្កើតបានជាប្រយោគ ដូច្នេះ ដើម្បីឲ្យបានស្គាល់ដំឡៃនៃប្រយោគនីមួយៗ គប្បីយើងដឹងដំឡៃ របស់ពាក្យ និងវាក្យាង្គ ដែលស្ថិតនៅក្នុងប្រយោគនោះដោយ ការធ្វើសម្ពន្ធ ។

តាមក្បួនវេយ្យាករណ៍យើងសង្កេតឃើញសម្ពន្ធពីរយ៉ាងគឺ៖

ក) សម្ពន្ធពាក្យ ឬ សម្ពន្ធវេយ្យាករណ៍

ខ) សម្ពន្ធប្រយោគ ឬ សម្ពន្ធក្លូង (មាលា)

២- សម្ពន្ធពាក្យ.- ដើម្បីនឹងសម្ពន្ធពាក្យយើងត្រូវដឹង៖

ក) ប្រភេទនៃពាក្យ គឺជាជានាម, គុណនាម, សព្វនាម កិរិយា, និបាត ៗលៗ

ខ) ភាពនៃពាក្យ គឺជាជា បុំលិង្គ, ឥត្ថីលិង្គ, នបុំសកលិង្គ ឯកវចនៈ ឬ ពហុវចនៈ ៗ

គ) មុខងារនៃពាក្យ គឺជាប្រធាន, គុណបទ ឬជាកម្មបទ ៗលៗ

៣- សម្ពន្ធប្រយោគ.- ដើម្បីនឹងសម្ពន្ធប្រយោគយើងត្រូវដឹង៖

ក) ចំនួនឃ្លាង្គ ដែលស្ថិតនៅក្នុងប្រយោគនោះ ៗ

ខ) ប្រភេទនៃឃ្លាង្គនីមួយ ៗ ៗ

គ) មុខងារ របស់ឃ្លាង្គនោះ ៗ

ឧទាហរណ៍

១– សម្ពន្ធពាក្យ ឬ សម្ពន្ធវេយ្យាករណ៍

សិស្សរៀនវិជ្ជា ។

របៀបសម្ពន្ធ.–

សិស្ស: នាម បុំល្លិង្គ ឯកវចន: ប្រធានរបស់រៀន ។

រៀន: កិរិយាសព្ទ បច្ចុប្បន្នកាល បឋមបុរស ឯកវចន: មានសិស្សជាប្រធាន ។

វិជ្ជា: នាម ឥត្ថីលិង្គ ឯកវចន: កម្មបទ របស់រៀន ។

២– សម្ពន្ធប្រយោគ ឬ សម្ពន្ធក្ឃ្ឃ័

របៀបសម្ពន្ធ.–

គ្រូប្រាប់ចៅសុខឲ្យរត់ ចៅសុខក៏ធ្វើតាមបង្គាប់ ព្រោះវាខ្លាចគាត់ធ្វើទណ្ឌកម្ម ។

របៀបសម្ពន្ធ.–

ក្ឃ្ឃ័ប្រយោគនេះមាន ៣ វាក្យាង្គ ៖

ក) គ្រូប្រាប់ទៅចៅសុខឲ្យរត់ វាក្យាង្គគោល ។

ខ) ចៅសុខធ្វើតាមបង្គាប់ វាក្យាង្គធំ ។

គ) ព្រោះវាខ្ជិលគាត់ធ្វើទណ្ឌកម្ម វាក្យាង្គបន្ត ដោយព្រោះ ជាកម្មប្រាប់ហេតុ ប្រាប់ទំនងរបស់វាក្យាង្គធំ ។

## មុខងាររបស់ប្រធាន

អត្ថន័យ.— ប្រធាន គឺជាពាក្យសំរាប់សំគាល់ថា អ្នកណាជាអ្នកធ្វើនូវអំពើ ឬដំណើរនៃកិរិយាឲ្យសំដែងឡើង ។

គេអាចរកប្រធានឃើញក្នុងប្រយោគនីមួយ ៗ ដោយដាក់នៅមុខកិរិយានូវសំនួរដូច្នេះ៖

អ្នកណា? ឧ. ឆ្កែស៊ីបាយ... អ្នកណាស៊ីបាយ? ឆ្កែ ស៊ីបាយ ដូច្នេះ ឆ្កែជាប្រធានរបស់កិរិយាស៊ី ។ ពាក្យសួរថា អ្នកណានេះ ប្រើបានតែចំពោះសត្វនឹងមនុស្ស ឯចំពោះវត្ថុវិញ គេសួរថា អ្វី? ឧ. ភ្លើងឆេះផ្ទះ ។ អ្វីឆេះផ្ទះ? ភ្លើង ឆេះផ្ទះ ដូច្នេះ ភ្លើងជាប្រធានរបស់កិរិយាឆេះ ។ ប្រធានដែលប្រើ

សំរាប់ ជាអ្នកធ្វើអំពើឲ្យកិរិយាស័ព្ទ ដូនប្រើដោយពាក្យមួយម៉ាត់ ដូចពាក្យថា ឆ្កែ ស៊ីបាយ ដូនកាលដោយពាក្យច្រើនម៉ាត់ ដូចពាក្យថា ឆ្កែសតាម៉ែនស៊ីបាយ ដូច្នេះពាក្យ ឆ្កែសតាម៉ែន ជាប្រធានរបស់ស៊ី ។

## ប្រភេទនៃប្រធាន

ប្រភេទរបស់ប្រធានក្នុងភាសាខ្មែរ អាចយកមកប្រើបានគឺ៖

នាម.– ដូចឧទាហរណ៍ថា៖ គោស៊ីស្មៅ ។ គោ ជានាមប្រធានរបស់កិរិយាស៊ី ។

សព្វនាម.– (ប្រើបានតែបុរិសសព្វនាម) ដូចឧទាហរណ៍ថា៖ វាកំពុងទិញសៀវភៅសរសេរ ។ វា ជាប្រធានរបស់កិរិយាទិញ ។

## ការហាត់

១– ចូររកប្រធានរបស់កិរិយាដែលស្ថិតនៅក្នុងប្រយោគដូចតទៅ៖

– ខ្ញុំបានសង់សាលាមួយខ្នង ដើម្បីទុកឲ្យសិស្សានុសិស្សរៀនវិជ្ជាៗ ក្បួនវិទ្យាសាស្ត្របានញុំាងសតិមនុស្សយើងឲ្យលះបង់ជំនឿខុសគន្លងជីវភាពៗ

ចូរធ្វើឲ្យហើយទៅ តែទុកនៅអ្នកមុខតែទទួលការខាតបង់ជាប្រាកដៗ

គប្បីទុកកខ្វះទៅ ព្រោះយើងធ្លាប់បានខ្វះហើយៗ

២– ចូរបំពេញប្រធានកន្សោមប្រយោគខាងក្រោមនេះៗ

...រៀនវិជ្ជាដើម្បីចិញ្ចឹមជីវិតៗ ...ត្រូវដឹងគុណចំពោះមាតាបិតាព្រោះ ...បានបីបាច់ថែរក្សាយើងតាំងពីតូចមកៗ គប្បី ... យកវត្ថុនោះឲ្យបាន ព្រោះឯងយកទៅធ្វើឲ្យបាត់ៗ

## មុខងាររបស់គុណបទ

អត្ថន័យ.– គុណបទ ជាពាក្យសំរាប់សម្រេចនូវលក្ខណៈឲ្យនាម ឯពាក្យដែលត្រូវធ្វើជាគុណបទនោះមានតែគុណនាមប៉ុណ្ណោះ ដូចពាក្យថា៖ គោខ្មៅស៊ីស្មៅ ៗ ពាក្យខ្មៅ

ជាគុណនាមបានបន្ថែមគុណភាពដល់ពាក្យគេ គឺប្រាប់ឲ្យដឹងថាគេនេះមានសម្បុរខ្មៅ ដូច្នេះខ្មៅមានមុខងារជាគុណបទរបស់គេ ។

## មុខងាររបស់កម្មបទ

អត្ថន័យ.— ពាក្យសំរាប់រងអំពើរបស់កិរិយា ឬ បំពេញន័យឲ្យកិរិយា ហៅថា..កម្ម ។

ប្រភេទរបស់កម្មក្នុងភាសាខ្មែរអាចយកមកប្រើបានគឺ ៖

នាម.— ១. សេះអូសរទេះ ។ រទេះជាកម្មរបស់កិរិយាអូស ។

សព្វនាម.— (ប្រើបានតែបុរិសសព្វនាម) ១. ឪពុកខ្ញុំវាយខ្ញុំ ។ ខ្ញុំជាកម្មរបស់កិរិយាវាយ ។

## កម្មរបស់កិរិយា

ក) ភាពរបស់កម្មបទ

បើតាមសេចក្តីសង្កេត អំពីភាពរបស់កម្មបទ យើងអាចចែកកម្មជាពីរយ៉ាងគឺ៖

# សកម្មបទនិងអកម្មបទ

១– សកម្មបទ.– សព្ទឬពាក្យណាដែលទទួលរងអំពើរបស់កិរិយាដោយត្រង់ ឬដោយចំ ៗ ហៅថាសកម្មបទ ដូចឧទាហរណ៍ថាៈ ចៅសុខទៅសាលា ។ សាលាទទួលរងអំពើរបស់កិរិយាទៅដោយត្រង់ៗ ។

២– អកម្មបទ .– សព្ទឬពាក្យណាដែលទទួលរងអំពើដោយមិនចំ គឺមានកាយតនិបាតឬនិបាតទៅឃាំងខាងមុខសព្ទនោះឬពាក្យនោះមានមុខងារជាអកម្មបទ ដូចឧទាហរណ៍ថាៈ គ្រូអង្គុយលើកៅអី ។ ពពោលចំពោះខ្ញុំ ។ កៅអី និង ខ្ញុំ ជាអកម្មបទរបស់កិរិយា អង្គុយ និង ពោល ។

## សេចក្តីសង្កេត

១). ន័យរបស់កម្មបទ

បើសង្កេតតាមន័យរបស់កម្មបទ យើងអាចចែកជាពីរ

យ៉ាងគឺៈ កម្មរងអំពើ នឹងកម្មប្រាប់តាមដំណើរ ហេតុ ឬ ប្រាប់តាមកាលៈទេសៈ ។

១– កម្មរងអំពើ កម្មរងអំពើសំដៅយកមនុស្សសត្វ ឬវត្ថុណាដែលចាំបំពេញអំពើរបស់កិរិយាសព្ទ សំរាប់បញ្ជាក់នូវន័យរបស់កិរិយា ។

ឧ: អ្នកស្រែបររទេះ ។ កម្មរងអំពើរបស់កិរិយាបរគឺ រទេះ។ កូនក្មេងដើរលើកន្ទេល ។ កម្មរងអំពើរបស់កិរិយាដើរគឺ កន្ទេល ។ កម្មរងអំពើជួនជា សកម្មបទ ជួនជា អកម្មបទ ។

## ការហាត់

១– ចូរស្រង់ពាក្យទាំងឡាយដែលស្ថិតនៅក្នុងនខសញ្ញា នៃប្រយោគខាងក្រោមនេះដោយប្រាប់មុខងារ ។

ជាតិនិងលទ្ធិប្រជាធិបតេយ្យ – លទ្ធិប្រជាធិបតេយ្យផ្ដាញ់ (នូវមនុស្សជិះជាន់មនុស្ស) ។ ឯមនុស្សជិះជាន់មនុស្សយ៉ាងឃោរឃៅជាទីបំផុតស្ថិតនៅ (ក្នុងករណី) ជាតិជិះ

ជាន់ជាតិ ៗ ហេតុនេះលទ្ធិប្រជាធិបតេយ្យការពារ (មនុស្ស) ការពារជាតិអំពី (ពុត) ជិះជាន់គ្នាព្យាយាមឲ្យមាន (សាមគ្គី) (ភេទមនុស្ស) នឹង (ភេទជាតិ) ទៅវិញទេ ៗ (គំរេត)

ការណើយកិច្ចការ.– នូវមនុស្ស សកម្មបទ របស់ កិរិយាបំផ្លាញ ៗ

២– ចូរគូសបន្ទាត់មួយពីក្រោមសកម្មបទ និងបន្ទាត់ពីរ ពីក្រោមអកម្មបទ នូវពាក្យក្នុងប្រយោគខាងក្រោម ៗ

កុំធ្វេសប្រហែសក្នុងការស៊ីនិងការផឹក.–

ចូរយើងជៀសវាងសេចក្ដីប្រមាទក្នុងការផឹក និងការស៊ី មាន ទំនងដូចជាយើងដើរចូលទៅក្នុងព្រៃ ដែលមានបន្លាច្រូងច្រាង យើងត្រូវតែដើរសន្សឹម ៗ កុំឲ្យស្រពាន់មិនឲ្យបន្លាមុតជើងយើង យ៉ាងណា ការស៊ីនិងការផឹកក៏ត្រូវតែប្រយ័ត្ន ដូច្នោះដែរ ៗ

(ប ឈុំ)

ការណើយកិច្ចគំរូ — ចូរយើងជៀសវាង សេចក្ដីប្រមាទក្នុង ការផឹក នឹង ការស៊ី ។

## ២– កម្មប្រាប់ដំណើរហេតុឬប្រាប់កាលៈទេសៈ

កម្មប្រាប់ដំណើរហេតុ ឬ ប្រាប់កាលៈទេសៈ បញ្ជាក់អំពើរបស់កិរិយាឲ្យដឹងកន្លែង ពេល ហេតុ គោលបំណង, សេចក្ដីកំណត់ សេចក្ដីប្រៀបធៀប ។ ដើម្បីនឹងឲ្យច្បាស់ក្នុងការរកកម្មទាំងនេះ ត្រូវធ្វើសំនួរថា៖ ឯណា ? កាលណា ? ដូចម្ដេច ? ព្រោះហេតុអ្វី ។ល។ ឧ. ប្អូនខ្ញុំដេកលើគ្រែ ។ ប្អូនខ្ញុំដេកឯណា ? លើគ្រែ គ្រែ ជាកម្មប្រាប់កន្លែងរបស់ដេក ។

— ខ្ញុំទៅសាលាអំពីព្រឹក ។ ខ្ញុំទៅសាលាអំពីកាលណា ? ឬថ្មើរណា ? អំពីព្រឹក ។ អំពីព្រឹក បញ្ជាក់ពេលរបស់កិរិយាទៅ ។ អំពីព្រឹកជាកម្មប្រាប់ពេលរបស់ទៅ ។

— យើងត្រូវធ្វើការដោយព្យាយាម ។ យើងត្រូវធ្វើការដោយប្រការយ៉ាងណា ? ដោយព្យាយាម ។ ព្យាយាមបញ្ជាក់

ប្រការរបស់កិរិយាធ្វើការ ។ ព្យាយាមជាកម្មប្រាប់ប្រការរបស់ធ្វើ ។

— សន្ធានទាំងឡាយកើតព្រមព្រោះសេចក្ដីល្អ ។ សន្ធានទាំងឡាយកើតព្រមព្រោះហេតុអ្វី ? — ព្រោះសេចក្ដីល្អ ។ សេចក្ដីល្អ បញ្ជាក់ហេតុដល់កិរិយាកើតព្រម ។ សេចក្ដីល្អ ជាកម្មប្រាប់ហេតុរបស់កិរិយាកើតព្រម ។

— ខ្ញុំសង់សាលានេះ ដើម្បីប្រយោជន៍សាធារណៈ ។ ខ្ញុំសង់សាលានេះដើម្បីអ្វី? ឬមានបំណងយ៉ាងណា? ខ្ញុំសង់សាលាដើម្បីប្រយោជន៍សាធារណៈ ។ ប្រយោជន៍សាធារណៈ បញ្ជាក់គោលបំណងឲ្យកិរិយាសង់ ។ ប្រយោជន៍សាធារណៈ ជាកម្មប្រាប់គោលបំណងរបស់កិរិយាសង់ ។

សៀវភៅនេះមានរាងដូចជាសៀវភៅខ្ញុំ ។ សៀវភៅនេះមានរាងដូចអ្វី? ដូចសៀវភៅខ្ញុំ ។ សៀវភៅខ្ញុំ បញ្ជាក់សេចក្ដីប្រៀបធៀបរបស់កិរិយាមាន ជាកម្មប្រាប់សេចក្ដីប្រៀបធៀបរបស់មាន ។

**កម្មបំពេញបទ** កម្មបំពេញបទគឺកម្មណាដែលបំពេញន័យឲ្យនាមដែលភ្ជាប់ពាក្យទាំងនោះដោយអាយតនិបាតពួកខ្លះ ។

១. ឆ្នុករបស់ខ្ញុំ ។ ខ្ញុំ ជាកម្មបំពេញបទរបស់ឆ្នុក ។ ឆ្នុករបស់អ្នកណា? ឆ្នុករបស់ខ្ញុំ ។

– កំឡាំងនៃសេចក្ដីមានៈ ។ សេចក្ដីមានៈជាកម្មបំពេញបទរបស់កំឡាំង ។ កំឡាំងនៃអ្វី? កំឡាំងនៃសេចក្ដីមានៈ

កម្មបំពេញបទជួនកាលជានាម ជួនកាលជាសព្វនាម ។

## ការហាត់

១– ចូរបញ្ជាក់មុខងាររបស់ពាក្យទាំងឡាយដែលស្ថិតនៅក្នុងខសញ្ញានៃប្រយោគខាងក្រោមនេះ ។

– សូរសព្ទវេលាព្រឹក.– (ព្រឹកមិញ) សូរសព្ទកាំភ្លើងបានបញ្ចេញនៅខាងក្រៅ (ក្រុង) ។ មនុស្សម្នាផ្អើលឆោឡោព្រោះ (ភ័យ) ចូលមកហើយ ប៉ុន្តែការស្ងៀមស្ងាត់របស់ (អ្នកស្រុក) ក៏កើតទៅវិញដោយពុំមាន (អន្តរាយ) អ្វីឡើយ ។

២– ចូរធ្វើប្រយោគដោយប្រើកម្មមានមុខងារផ្សេង ៗ

ករណីយកិច្ចគំរូ– ត្រីហែលក្នុងទឹក (ទឹកជាកម្មប្រាប់កន្លែងរបស់ហែល ៗ ភូមិខ្ញុំសង់នៅលើទួល (ខ្ញុំជាកម្មបំពេញបទរបស់ភូមិ) (ទួលកម្មប្រាប់កន្លែងរបស់សង់) ៗ

## សារុបការបាត់

លំដាប់នោះរាជហង្សហិរណ្យគិក សួរឡើងដោយសេចក្ដីឆ្ងល់ថា៖ ចុះអ្នកណាដុតបំផ្លាញបន្ទាយយើងសត្រូវឬប្រជាជនក្នុងបន្ទាយដែលចូលដៃជាមួយនឹងសត្រូវ? ៗ ចាក្រពាកសិរិវឌ្ឍៈជាប្រធានរដ្ឋមន្ត្រី ឆ្លើយឡើងថា៖ «ទេវបាទ! ក្អែកមេឃពណ៌ព្រមទាំងបរិវារដែលលោកម្ចាស់ជាប់ចិត្ត ឥតហេតុផលនេះឯងបាត់មុខមិនឃើញនៅទីនេះទេ បើដូច្នេះប្រហែលជាក្អែកក្បត់នេះឯងវាដុតបន្ទាយយើង» ៗ រាជហង្សហិរណ្យគិករំពឹងទ្រឹងមួយស្របក់និយាយតបទៅថា៖ អើរឿងនេះបើពិតដូច្នេះមែនគឺជាវាស្នាអាក្រក់នៃយើងនេះតែម្ដង ៗ ប–ខាត់ (ស្រីហិតោបទេស)

១– ចូរសម្ពន្ធពាក្យ– រាដុតបន្ទាយ ។

២– ចូរឲ្យមុខងារពាក្យខាងក្រោមនេះ

សេចក្ដីឆ្ងល់, យើង (បំផ្លាញបន្ទាយយើង) បន្ទាយ (ប្រជាជនក្ដង់បន្ទាយ) សត្រូវ, យើង (រាស្ត្រអាក្រក់នៃយើង)

ចូរសម្ពន្ធប្រយោគថា «ចាក្រពាកសិរជ្រ: រហូតដល់ ... រាដុតបន្ទាយយើង ។

# សម្ពន្ធវេយ្យាករណ៍ ឬសម្ពន្ធពាក្យ

សម្ពន្ធវេយ្យាករណ៍ គឺជាការបង្រៀនបទនៃពាក្យនីមួយៗក្នុងប្រយោគដើម្បីឲ្យដឹង ថាបទណា ចូលទៅរកបទណា និងឲ្យដឹងប្រភេទ លិង្គវចនៈព្រមទាំងមុខងារនៃពាក្យទាំងនោះផង ។

ពាក្យដែលត្រូវសម្ពន្ធគឺៈ

នាម, គុណនាម, សព្វនាម, កិរិយាស័ព្ទ, អាយតនិបាត, និងនិបាតស័ព្ទ ។

## សម្ពន្ធនាម

ដើម្បីនឹងសម្ពន្ធនាម យើងត្រូវដឹងៈ

១— ប្រភេទ= សាធារណនាម, អសាធារណនាម, ករណនាម, ការកនាម, សមូហនាម, ក្រិតនាមឬសមាសនាម

២— លិង្គ= បុំលិង្គ, ឥត្ថីលិង្គ, ឬនបុំសកលិង្គ (អលិង្គ)

៣— វចនៈ= ឯកវចនៈ ឬពហុវចនៈ

៤-មុខងារ= ប្រធាន កម្មរង់អំពើ ប្តកម្មបំពេញបទ-

## ប្រភេទរបស់នាម

អត្ថន័យ.— អ្វីទាំងពួងដែលនៅក្នុងលោក ទោះមាន វិញ្ញាណក្ដី ឥតវិញ្ញាណក្ដី មានរូបក្ដី គ្មានរូបក្ដី ដែលមានឈ្មោះ ហៅបានដូចពាក្យថា៖

មនុស្ស, សត្វ, ទឹក, ដី, ភ្លើង, ខ្យល់; អាកាស ។ល។ ហៅថា នាម ប្រែថា "ឈ្មោះ" ។

## នាមសព្ទ

អត្ថន័យ.— ដែលហៅថានាមសព្ទគឺ "សំឡេងឬសំដី ដែលលាន់ឮប្រាកដចំពោះឈ្មោះនោះ ។ នាមសព្ទប្រែថា "សំដី សំដែងនូវឈ្មោះ" ។

នាមសព្ទមានបីយ៉ាងគឺ នាមនាម-គុណនាម-និង សព្វនាម ។

## នាមនាម

អត្ថន័យ.— នាមនាមគឺជាឈ្មោះនៃអ្វីទាំងពួង ទោះមាន

រូបក្តី ឥតរូបក្តី ដែលគេសន្មតឈ្មោះសម្រាប់ទុកហៅបាន ដូចពាក្យថា៖ មនុស្ស; សត្វ, ឈើ, ទន្លេ, ស្រុក, ស្រែ, សីល, ទានជាដើម ។ នាមនាមចែកជាពីរយ៉ាងគឺ៖

ក)– នាមរូប ឬ រូបនាម គឺមានរូបដូចជា មនុស្ស, សាលា, ផ្ទះ កុដិជាដើម ។

ខ)– នាមអរូប ឬ អរូបនាម គឺនាមដែលឥតរូបដូចជា ចិត្ត គំនិត ទុក្ខ សុខ ព្រួយ សប្បាយជាដើម ។

នាមនាមក្នុងភាសាខ្មែរមាន ៧ យ៉ាងគឺ:

សាធារណនាម, អសាធារណនាម, ការកនាម, កិតនាម (នាមក្រិត) សម្ពន្ធនាម និងសមាសនាម ។

## សាធារណនាម

នាមដែលសម្តែងឈ្មោះពុំទាន់ច្បាស់លាស់ ដូចពាក្យថា មនុស្ស សត្វ ដែន ក្រុងជាដើម នាមទាំងឡាយនេះមិនទាន់

ប្រាកដឡើយ មិនដឹងជាមនុស្សណា សត្វណា ដែនណា ក្រុងណា គឺទូទៅទាំងអស់ ដូចឧទាហរណ៍ៈ ផ្ទះខ្ញុំសង់ពីឈើ ប្រកក្បឿង ។ ផ្ទះ ឈើ ក្បឿងជាសាធារណនាមរូប ។

ឧ. ថ្ងៃនេះខ្ញុំទញ់គំនិតណាស់ មិនសូវសប្បាយទេ ព្រោះចិត្តខ្ញុំរវើរវាយ ។

គំនិត ចិត្ត ជាសាធារណនាមអរូប ។

## អសាធារណនាម

នាមដែលសម្ដែងឈ្មោះប្រាកដមិនទូទៅបាន ដូចពាក្យថា ក្រុងកម្ពុជា ទន្លេមេគុង ភ្នំពេញ-ឧណ្ណាលោម នរោត្តម ជាដើម ហៅថា អសាធារណនាម ។ ឧ. រាជធានីកម្ពុជា គឺភ្នំពេញ មានទន្លេមេគង្គ បែកជាបួនជាគ្រឿងចំណាំ

កម្ពុជា ភ្នំពេញ មេគង្គ ជាអសាធារណនាម ។

## ការកនាម

ដែលហៅថា ការកនាម គឺនាមដែលប្រាប់រូបអ្នកធ្វើ ឬអ្នកសម្រេចអំពើដូចពាក្យថា អ្នកដំណើរ អ្នកនេសាទ អ្នក

ជំនួញ កសិករជាដើម ។ ឧ. អ្នកដំណើរម្នាក់និយាយប្រាប់ខ្ញុំថា នៅស្រុកយើងសព្វថ្ងៃនេះ មិនសូវមានអ្នកជំនួញច្រើនទេ មាន តែកសិករ នឹងកម្មករ ឯអ្នកទេសាចក៏មិនសូវមានដែរ ។

អ្នកដំណើរ, អ្នកជំនួញ កសិករ កម្មករ អ្នកទេសាច ជាការកនាម ។

ចំណាំ ៖– ពាក្យបាលីណាជាការកនាម ត្រូវចុះបច្ច័យជា គ្រឿងចំណាំស្រេចដូចពាក្យថា ឧបត្ថម្ភក៍ ពុទ្ធសាសនិក គឺមាន ចុះក បច្ច័យនឹងឥក បច្ច័យ ។

# ករណនាម

អត្ថន័យ ៖– នាមដែលប្រាប់នូវអំពើដូចពាក្យថា៖ សេចក្ដីព្យាយាម ការដើរ, ឬការប្រមាញ់, ការឈ្នះ សេចក្ដីប្រមាទ ឬការទំនុកបំរុងជាដើម ហៅថា ករណនាម ។

ឧ. ព្រានប្រមាញ់នេះមានសេចក្ដីឧស្សាហ៍ ក្នុងការធ្វើដំណើរទៅបរបាញ់ដើម្បីនឹងយកសត្វមកឧបត្ថម្ភ គ្រួសារគាត់ ។

សេចក្ដីឧស្សាហ៍ ការធ្វើដំណើរ ជាករណនាម ។

# នាមក្រិត ឬ កិតនាម

អត្ថន័យ.– នាមសព្ទណា ដែលមានកំណើតជាកិរិយាសព្ទឬជាគុណសព្ទ នាមសព្ទនោះហៅថា កិតនាម ដូចពាក្យជា៖ កំណាត់ < កត់, បំណែក < បែក, ទំហំ < ធំ ។

ឧ. ដំណើរនេះ យើងមិនអាចនឹងកំណត់បានទេ ព្រោះគ្មានអ្វីជាជំនួយឬជាពុំនឹងសោះ ។

ដំណើរ-កំណត់-ជំនួយ-ពុំនឹងជាកិតនាម ។

# សមូហនាម

អត្ថន័យ.– ដែលហៅថា សមូហនាម គឺនាមដែលជាឈ្មោះរួបរួម ទីប្រជុំនៃមនុស្ស, សត្វឬវត្ថុអ្វីនីមួយៗ ដូចពាក្យថា ហ្វូងសត្វ ប្រជុំជន បក្សសត្វឬសត្វស្លាប មនុស្សនិករ គណជាតិ-ចតុប្បាទ-ទ្វេបាទជាដើម ។

ឧ. បណ្ដាជនទាំងឡាយតែងរក្សាសីល មិនដែលទៅសម្លាប់សត្វចតុប្បាទ ទ្វេបាទ ឬ បក្សាបក្សីណាមួយឡើយ ។

បណ្ដាជន ចតុប្បាទ ទ្វេបាទ បក្សាបក្សី ជាសមូហនាម ។

ព្រឹក ៗ ឡើងគេឃើញសន្សើមធ្លាក់មកលើតិណជាតិនិង រុក្ខជាតិទាំងឡាយ ។

តិណជាតិ, រុក្ខជាតិ ជាសមូហនាម ។

## សមាសនាម

អត្ថន័យ.— នាមសព្ទតាំងពី ២ ម៉ាត់ឡើងទៅ ដែលបំព្រួញទៅជាពាក្យមួយម៉ាត់ហៅថា សមាសនាម ។ សមាសនាមមានពីរយ៉ាងគឺ៖ សមាសនាមបាលី និង សមាសនាមខ្មែរ ។

១— សមាសនាមបាលី ដូចពាក្យថា៖ សិស្សានុសិស្ស ប្រជាធិបតេយ្យ-ចត្រង្គ, ចតុរាបាយ, ទូរសព្ទ, ទូរលេខ ។

២— សមាសនាមខ្មែរ ដូចពាក្យថា៖ ដើមសណ្ដាន់-ចាំកូមា គោសៀម, ជើងម៉ា ជង្គង់នាងជាដើម ។

១. ព្រះភូមិន្ទនរិន្ទនរបតី ទ្រង់យាងទៅសម្រាកក្រោម

ដើមពោធិ៍ ឈើដើងម៉ាមួយធំ ដើម្បីប្រាស្រ័យជាមួយទីង ប្រជានុកស្រ្ត ។

កុមិទ្រ និទ្រ នរបតី ដើមពោធិ៍ ដើងម៉ា ប្រជានុកស្រ្ត ជាសមាសនាម ។

# ភាពរបស់នាម

## លិង្គនិងវចនៈ

អ្វីដែលហៅថាលិង្គ ? អ្វីហៅថាវចនៈ ?

## លិង្គ

អត្ថន័យ.— លិង្គ គឺជាភេទសំរាប់សំគាល់នាមសត្វ ដែលប្រព្រឹត្តទៅដោយអាការៈប្លែក ៗ គ្នា ដូចពាក្យថា៖ មនុស្សប្រុស, ឆ្កែញី-មាន់ឈ្មោល-មនុស្សខ្ទើយ ... ។ លិង្គមានបីយ៉ាង គឺ៖ បុំលិង្គ ភេទប្រុស ឥត្ថីលិង្គ ភេទស្រី នបុំសកលិង្គ ភេទមិនមែនប្រុសមិនមែនស្រី គឺខ្ទើយ ។

តាមក្បួនបញ្ញត្តិនៃលោក នាមរបស់មនុស្សប្រុស ឆ៏ារបស់

មន្ត្រីសឹងជាបុំលិង្គ ។ ឯនាមរបស់មនុស្សស្រី-ស្រុក-ភូមិ-នគរ-វគ្គ-ខេត្ត សឹងជាឥត្ថីលិង្គ ។ ចំណែកឯនាមរបស់មនុស្សខ្ទើយជា នបុំសកលិង្គ ។

ម្យ៉ាងទៀតវត្ថុដែលជាល្បែងលេងសឹងជាឥត្ថីលិង្គដែរ ដូចជាអង្គុញ-មេប្រុំកជាដើម ។

ពាក្យដែលសម្រាប់ប្រើជាបុំលិង្គដូចពាក្យថា៖ តា-ឪ-មា-ពូ-អយ្យកោ-កុមារ-យក្ស-ភិក្ខុ-សាមណេរ-ពានរ ជាដើម ។

ពាក្យដែលប្រើសម្រាប់ ឥត្ថីលិង្គ ដូចពាក្យថា៖ យាយ ម៉ែ មីង កុមារី រទី ចោរី-ភិក្ខុនី មាតុច្ឆា ព្រាហ្មណី ។

កំណត់ចំណាំ — តាមធម្មតាពាក្យណាដែលក្លាយមកពីភាសាបាលី គេសំគាល់បានថាពាក្យនោះជាពាក្យឥត្ថីលិង្គ ដោយពាក្យនោះបង្ហើយនឹងស្រៈ អី ដូចពាក្យថា៖ ភិក្ខុនី កុមារី ព្រាហ្មណី ។ល។ ជួនកាលបង្ហើយដោយស្រៈ អា ដូចពាក្យថា៖ អយ្យកា មាតុច្ឆា តារា ជាដើម ។

ខ. កុមារនេះដឹកគោញី ទៅឲ្យស៊ីស្មៅ ។ កុមារជាបុល្លិង្គ; គោញីជាឥត្ថីលិង្គ; ឯស្មៅនេះទើងកំណត់ជាលិង្គអ្វីពុំបាន ដូច្នេះគួរឲ្យឈ្មោះថា អលិង្គ ព្រោះមិនមែនញី-ឈ្មោល ឬខ្ទើយឡើយ គឺគ្មានលិង្គឡើយ ។

## វចនៈ

អត្ថន័យ.– ពាក្យសម្រាប់ញែកចំនួនសត្វនីមួយ ៗ ឲ្យដឹងថា តិច ឬ ច្រើន ហៅថា វចនៈ ដូចពាក្យថា ក្មេង ៗ ស្រី ៗ, មនុស្សទាំងឡាយ អ្នកទាំងពួងជាដើម ។ វចនៈក្នុងភាសាខ្មែរនឹងបាលីមានពីរយ៉ាងគឺ ៖

ឯកវចនៈ នឹង ពហុវចនៈ

### ក– ឯកវចនៈ

អត្ថន័យ – វចនៈដែលជាគណនាចំនួនតែមួយហៅថា ឯកវចនៈ ដូចពាក្យថា៖ ប្រុស, ស្រី, គោ, ក្មេង ។

ឧ. មនុស្សនេះរៀនវិជ្ជាគុន ។ មាន់ស៊ីស្រូវ ។ គោរបស់ចៅឃិមស៊ីសំណាបក្នុងស្រែ ។

វិជ្ជាគុន - មាន់ ស្រូវ សំណាប ស្រែ ទាំងអស់នេះ ជាឯកវចនៈ ។

## ១– ពហុវចនៈ

អត្ថន័យ.– ពហុវចនៈគឺវចនៈណាដែលប្រាប់ចំនួនច្រើនតាំងពី២ឡើងទៅ ដើម្បីនឹងញុំាងពាក្យទាំងឡាយ ឲ្យទៅជាពហុវចនៈ គេត្រូវដាក់ពីខាងមុខនាមជាឯកវចនៈ នូវពាក្យទាំងឡាយ, ទាំងពួង, ទាំងអស់, នឹងលេខទោ (ៗ) ឬសំឡាសព្ទដូចពាក្យថា៖ ក្មេងៗ កូនទាំងឡាយ ធម៌ទាំងពួង មនុស្សទាំងអស់ គោច្រើនមួយ ។

ឧ. អ្នកទាំងឡាយចូរញុំាងក្មេងៗ ឲ្យរៀនទៅ ។

អ្នក ក្មេង ជាពហុវចនៈ ។

គំនិតចំណាំ.– ពាក្យខ្លះដែលចេញពីបាលីនឹង

សំស្រ្កឹត មានវចនៈជាទីសំគាល់របស់វានៅទីធរូបស្រាប់តែម្ដង ដូចពាក្យថា៖ រុក្ខ (ឯកវចនៈ) រុក្ខា (ពហុវចនៈ) យក្ស (ឯកវចនៈ) យក្សា ពហុវចនៈ) ។

## មុខងាររបស់នាម

នាមនាមអាចធ្វើជាប្រធាន កម្មវត្ថុអំពើនិងកម្មបំពេញបទ

១. អ្នកស្រែធ្វើការក្នុងស្រែ ។ អ្នកស្រែ ជាប្រធានរបស់ធ្វើការ; ក្នុង ស្រែ ជាកម្មវត្ថុអំពើរបស់ធ្វើការ ។

២. នៅក្នុងភូមិខ្ញុំមានចោរច្រើនណាស់ ។ ភូមិខ្ញុំ ប្រធានរបស់មាន; ចោរ កម្មវត្ថុអំពើរបស់ មាន ។

៣. ឯករាជ្យនៃប្រទេសកម្ពុជា បានមកដោយស្នាព្រះហស្តនៃសម្ដេចព្រះឧបយុវរាជ ។ ឯករាជ្យប្រធានរបស់បានមក; ប្រទេសកម្ពុជា កម្មបំពេញបទរបស់ឯករាជ្យ; ស្នាព្រះហស្ត កម្មវត្ថុអំពើរបស់បានមក ។ សម្ដេចព្រះឧប-យុវរាជ កម្មបំពេញបទរបស់ស្នាព្រះហស្ត ។

( ក្ដួ មើលត្រង់មេរៀនអំពីកម្មបទ )

## វិធីសម្ពន្ធនាមនាម

១– ចូរសម្ពន្ធនាមនាមដែលស្ថិតនៅក្នុងប្រយោគខាងក្រោមនេះ ។

ព្រះរាជដំណើរនៃសម្ដេចព្រះឧបយុវរាជ ទៅកាន់ប្រទេសចិនប្រជាមានិត្ត បាននាំមកនូវលទ្ធផលល្អ ពេញតាមសេចក្ដីបំណងរបស់ប្រជាជនខ្មែរគ្រប់រូប ។

ព្រះរាជដំណើរ= សមាសនាម អលិង្គ ឯកវចនៈ ប្រធានរបស់កិរិយាទៅ ។

សម្ដេចព្រះឧបយុវរាជ= សមាសនាមបុំលិង្គ ឯក-វចនៈ កម្មបំពេញបទរបស់ព្រះរាជដំណើរ ។

ប្រទេសចិនប្រជាមានិត្ត= អសាធារណនាម ឥត្ថីលិង្គ ឯកវចនៈ កម្មប្រាប់កន្លែងរបស់កិរិយាទៅ ។

លទ្ធផល= សមាសនាម អលិង្គ ឯកវចនៈ អកម្មរបស់កិរិយាបាននាំមក ។

សេចក្ដីបំណង= ករណនាម អលិង្គ ឯកវចនៈ កម្មប្រាប់លំអានរបស់កិរិយាពេញ ។

ប្រជាជនខ្មែរ= សមូហនាម អលិង្គ ពហុវចនៈ កម្មបំពេញបទរបស់សេចក្ដីបំណង ។

២– គំនិតអាក្រក់ ដែលធ្លាប់មើលងាយអ្នកស្រែនេះ ឯង ឈប់ប្រកាន់ខ្លះទៅ ។

គំនិត= ក្រិតនាម អលិង្គ ឯកវចនៈ ប្រធានរបស់កិរិយា មើលងាយ ។

អ្នកស្រែ= ការកនាម អលិង្គ ឯកវចនៈ សកម្មបទរបស់ មើលងាយ ។

## ការហាត់

ចូរសម្ពន្ធនាមសព្ទ ដែលជាអក្សរមូលក្នុងប្រយោគខាង ក្រោមនេះ ។

រាជធានីភ្នំពេញ.– បើគេជឿតាមកាលៈទេសៈ ដែលកន្លេងបានផ្ដាំមកហើយ ៗ បើគេជឿតាម រឿង ដែល

ពីយែរឡូទី បានតែងពី ដំណើរ គាត់មកកាន់ ប្រ-
ទេសខ្មែរ គេអាចសន្និដ្ឋានបានថា ភ្នំពេញ នៅជាក្រុង
មួយខ្សត់ខ្សោយជាដរាបមាន ផ្លូវ ស្ងាត់ឈឹង ស្មៅ ដុះទ្រុន
លើចិញ្ចើមផ្លូវឲ្យអផ្សុកក្រៃលែង ហើយមាន ដំរី ពីរ បី ដើរ
អូសជើងយឺតយោគគួរឲ្យស្រងេះស្រងោច ៗ អ្នកនិពន្ធ
សៀវភៅ ប្ញជធីយេសគ៌អង្គរ កាលពីឆ្នាំ ១៩០១ បាន
ថ្លែងថា៖ «គៀនប្រទេស បារាំង មួយជ្រុងតូចដែលមកដុះពន្លក
នៅកន្លែងនេះ ពិតជាគ្មាន ជីវិត រស់នៅយូរឡើយ ដោយមិន
ទាន់បានប៉ុន្មានឆ្នាំក៏មានសភាព ដូចជាទ្រុឌទ្រោមណាស់ទៅ
ហើយ ដោយគេបោះបង់ចោល» ៗ បូរនិមិត្តដ៏ក្រៀមក្រំនេះមិន
ពិតទេ ៗ ផ្ទុយទៅវិញបានរីកឡើងហើយទៅជាធានីមួយ មាន
ទ្រង់ទ្រាយប្រិមប្រិយធំឡើង នៅមាត់ទន្លេមេគង្គ ៗ ក្រៅពី
ការបង្ហាញនូវ កេរ្តិ៍ ដ៏ស្និតស្រពោន កម្ពុជរដ្ឋ រាជធានី
បានលាតសន្ធឹងនូវការសមសួនគួរជាទីពិតពិលរមិលមើល
នៃអ្នកទាំងពួង ៗ

កាលណា គេមកដល់នៅពេលព្រលប់ តាមទន្លេមេគង្គ គេឃើញពីចម្ងាយរូបភាពដំបូលស្រួច ៗ ឃើញដំបូលព្រះវិហារច្រើនជាអនេក ដែលនៅខាងចុងមានលំអរ ដោយក្បាច់រចនាយ៉ាងពិសិដ្ឋលិចឡើង ចង្អុលទៅលើអាកាសវេហាស៍ ៗ កាលណាគេឃើញព្រួញវែងនៃវត្តភ្នំ ឃើញរុក្ខាធំ ៗ ដុះព័ទ្ធជាជួរពណ៌បៃតងស្រស់ ហើយនឹងគិរិវិថី នៃកំពង់ចំណតធំ ៗ ដែលមានទូកថ្ងៃនឹងកប៉ាល់ចតជាជួរត្រៀបត្រា ៗ កាលណាគេឃើញវត្តអស់នេះរួចហើយ គេក៏មានសេចក្ដីងឿងឆ្ងល់ដែលប្លែកភ្នែកខុសពីគេក្នុងមជ្ឈដ្ឋានឥណ្ឌូចិន ៗ សភាពនេះមិនដូចជាសភាពណាមួយសោះ ដែលគេបានប្រទះភ្នែកមក កាលណាគេបានធ្វើដំណើរទៅប្រទេសនានានៃសហរដ្ឋ ៗ នៅពេលយប់គេស្មានថាមកជិតធានីមួយដែលមានរូបភាពដ៏សំបើម ដែលបរិបូណ៌ទៅដោយស្រមោលប្លែក ៗ នឹងគ្រឹះស្ថានដែលមានកំពូលស្រួច ៗ ហាក់ដូចជាកាំប្រមាកំពង់ដម្លើងប្រែងការពារខ្លួនវា ៗ សេចក្ដីចង់ដឹង ចង់យល់ ក៏កើតឡើងមួយរំពេច ៗ

ភ្នំពេញមិនមែនជាក្រុងមួយធម្មតាទេ ។

## សម្ពន្ធគុណនាម

ដើម្បីនឹងសម្ពន្ធគុណនាម យើងត្រូវដឹងៈ

១ ប្រភេទ.— បកតិគុណនាម, វិសេសគុណនាមឬអតិវិសេសគុណនាម ។

២ ភាព.— លិង្គនឹងវចនៈ

៣ មុខងារ.— គុណបទរបស់នាមណា ដែលគុណនាមនោះសំដែងលក្ខណៈឲ្យ ។

## ប្រភេទរបស់គុណនាម

អត្ថន័យ.— ពាក្យដែលសំដែង ឬប្រកាសនូវលក្ខណៈរបស់នាមនាម ឬធ្វើនាមនាមនោះឲ្យមានបទសម្រាប់សំគាល់ឲ្យដឹងថា ល្អ ឬ អាក្រក់ ធំ ឬ តូច ខ្ពស់ ឬ ទាប ដូចពាក្យថាៈ ល្អ, អាក្រក់ តូច ធំ ស ខ្មៅ ពាល ស្លូត គាប ល្ងង់ រាក់

ជ្រៅជាដើម គឺសំដៅយកសណ្ឋានទ្រង់ទ្រាយនឹងអាការៈលើសឡើង ឬថយចុះ របស់នាមនាម ហៅថា គុណនាម ។

១. ប្អូនខ្ញុំជាក្មេងល្ងង់ ។ ឈើដែលគេយកមកធ្វើផ្ទះនេះរឹង ។ បងខ្ញុំជាមនុស្សពាល ។ ល្ងង់, រឹង, ពាល ជា គុណនាម ។

កំណត់ចំណាំ.— ពាក្យពាលនេះជាគុណនាម កាលសំដែងលក្ខណៈរបស់នាមនាមក្នុងទីនេះ ពាលសំដែងលក្ខណៈនាមរបស់មនុស្ស ។ កាលណា «ពាល» នៅមុខកិរិយាសព្ទ «ពាល» ត្រូវជានាមនាមដូចពាក្យថា៖

«ពាលនាំឲ្យធ្លាក់ទៅក្នុងអបាយមុខ» ក្នុងប្រយោគនេះ ពាល ជានាមនាម ។

## គុណនាមបែកជាបីយ៉ាង គឺ:

បកតិគុណនាម វិសេសគុណនាម អតិវិសេសគុណនាម ។

បកតិគុណនាម.— គុណនាមណាដែលសំដែងលក្ខណៈរបស់នាមតាមធម្មតា មិនមែនប្លែកឬវិសេសជាងប្រក្រតី

ដូចពាក្យថា: ក្រាស ស្តើង វែង ខ្លី ប្រសើរ ប្រសប់ ។ល។ ហៅថា បកតិគុណនាម ។

ឧ. ផ្ទះនេះតូច; សៀវភៅនេះល្អ; សាច់សំពត់ដែលខ្ញុំយកមកកាត់ខោនេះម៉ត់ ។

តូច-ល្អ-ម៉ត់ ជា បកតិគុណនាម ។

## វិសេសគុណនាម

អត្ថន័យ.— វិសេសគុណនាម គឺគុណនាមណា ដែលសំដែងលក្ខណៈរបស់នាមនាមឲ្យ ប្លែកជាងប្រក្រតី តែមិនទាន់ថ្លៃថ្លា ឬថយថោកនោះទេ គ្រាន់តែសម្តែងឲ្យដឹងថាវិសេសជាងធម្មតាប៉ុណ្ណោះ ដូចពាក្យថា៖ ធំជាង តូចជាង សជាង ត្រូវជាង ល្អប្លែក មានប្រាជ្ញាប្លែក, ខ្ពស់គ្រាន់បើ... ។

ឧ. បងខ្ញុំខ្ពិលជាងខ្ញុំ ប៉ុន្តែប្អូនខ្ញុំរៀនពូកែជាងខ្ញុំ ។

ខ្ជិលជាង ពូកែជាង ជា វិសេសគុណនាម ។

## អតិវិសេសគុណនាម

អត្ថន័យ.— គុណនាមដែលសម្តែងលក្ខណៈរបស់នាម.

នាម ឲ្យវិសេសប្លែកបំផុត ដូចពាក្យថា សស្គុះ-ទ្មោយន៍ គួបពេក, ធំបណ្តាច់ ត្រជាក់បំផុត ជាដើមហៅថា អតិវិសេសគុណនាម ។

ឧ. ឪពុកខ្ញុំស្លូតណាស់ ហើយគាត់ជាអ្នកឆ្លាតបំផុត ។ ស្លូតណាស់ ឆ្លាតបំផុត ជា អតិវិសេសគុណនាម ។

## លិង្គ និងវចនៈ របស់គុណនាម

(ចូរមើលក្នុងវិធីសព្វនាម)

លិង្គ និង វចនៈ របស់គុណនាម ត្រូវប្រព្រឹត្តទៅតាម នាមដែលខ្លួនសម្តែងលក្ខណៈឲ្យ ។

ឧ. ស្រីពីរនាក់នេះចាស់ ចាស់ បកតិគុណនាម ឥត្ថីលិង្គ ពហុវចនៈ ។

ឧ. គោឈ្មោលនេះធាត់ណាស់, ធាត់ អតិវិសេសគុណនាម បុំលិង្គ ឯកវចនៈ ។

ឧ. ដើមត្នោតទាំងឡាយ ក្នុងស្រែនោះ ខ្ពស់ជាងដើមដូង, ខ្ពស់ វិសេសគុណនាម អលិង្គ ពហុវចនៈ ។

## មុខងាររបស់គុណនាម

គុណនាម មានមុខងារជា គុណបទ របស់នាមណា ដែលខ្លួនសម្តែងលក្ខណៈឲ្យ ។

ម. សៀវភៅដែលដាក់នៅលើតុនេះល្អ; ល្អ ជាគុណបទ របស់សៀវភៅ ។

ម. ស្រីចាស់នេះដើរទៅកាន់ផ្សារ, ចាស់ ជាគុណបទ របស់ស្រី ។

ម. ក្មេងតូច ៗ នេះរត់លេងក្នុងទីធ្លាដ៏ទូលាយ តូច ជាគុណបទរបស់ក្មេង ។ ទូលាយ ជាគុណបទរបស់ទីធ្លា ។

## វិធីសម្ពន្ធគុណនាម

ចូរសម្ពន្ធគុណនាមក្នុងប្រយោគខាងក្រោមនេះ

១— មនុស្សចិត្តអាក្រក់ មិនអាចទទួលនូវផលល្អបានទេ ។

អាក្រក់=បកតិគុណនាម បុំលិង្គ ឯកវចនៈ គុណបទរបស់ចិត្ត ។

ល្អ= បកតិគុណនាម អលិង្គ ឯកវចនៈ គុណបទរបស់លទ្ធផល ៗ

២– កុមារីទាំងឡាយនេះ ខ្ជិលណាស់ ៗ ស្រី ៗ ពូកែដាំស្លជាងបុរស ៗ

ខ្ជិល= អតិវិសេសគុណនាម ឥត្ថីលិង្គ ពហុវចនៈ គុណបទរបស់ស្រី ៗ

ពូកែ= វិសេសគុណនាម ឥត្ថីលិង្គ ពហុវចនៈ គុណ-បទរបស់ស្រី ៗ

៣– មនុស្សល្ងង់ មិនអាចគិតការអ្វីឲ្យហ្មត់ចត់បានទេ ៗ

ល្ងង់= បកតិគុណនាម បុំលិង្គ ឯកវចនៈ គុណបទរបស់មនុស្ស ៗ

ហ្មត់ចត់= បកតិគុណនាម អលិង្គ ឯកវចនៈ គុណបទរបស់ការ ៗ

# ការបោក

ប្ញសមន្ទគុណនាមទាំងឡាយ ដែលស្ថិតនៅក្នុងប្រយោគនៃអត្ថបទខាងក្រោមនេះ ។

## ទេសភាពរដូវប្រាំង

ក្នុងរដូវប្រាំងសែងព្រះអាទិត្យ បានបញ្ចេញតេជោធាតុដុតកំដៅក្បាលតាវល្ងីនិងជីវិតមនុស្សសត្វយ៉ាងខ្លាំងក្លាឥតត្រាប្រណី ។

ទេសភាពនៃបពិត មិនបានបញ្ចេញសកម្មភាពអ្វីងប៉ុន្មានទេ គ្រាន់តែមានការកំរើករញ្ជួយម្ដង ៗ តាមកម្លាំងខ្យល់ដែលនាំទាំងចំហាយក្ដៅមកផងនោះ ។ នៅលើវាលស្រែដ៏ធំទូលាយមានតែគោតីរ-បីប៉ុណ្ណោះ ដែលកំពុងបរិភោគស្មៅយ៉ាងព្រងើយគ្មានព្រួយសូរសព្ទអ្វី ក្រៅពីសម្លេងស្រងេះស្រងោចនៃសត្វវែងដែលកំពុងតែយំឆ្លើយឆ្លងគ្នានៅលើចុងឈើ ។

មហាមេឃខៀវស្រងាត់ ឥតមានពពកអ្វីមួយមកកាំងទេ ៗ កំដៅថ្ងៃតែតែបន្ថែមយ៉ាងខ្លាំងមកទៀត ៗ យូរ ៗ ខ្យល់បក់មកម្តង ៗ នាំទាំងក្លិនពិដោរនៃបុប្ផាជាតិនានា ដែលដុះនៅក្បែរនោះមកផង ៗ

ព្រហ្មវីរៈ

# សម្ពន្ធសព្វនាម

ដើម្បីនឹងសម្ពន្ធសព្វនាមយើងត្រូវដឹង៖

១– ប្រភេទ= បុរិសសព្វនាម ឬវិសេសនសព្វនាម (និយម ឬ អនិយម)

២– ភាព= លិង្គ នឹង វចនៈ

៣– មុខងារ= ជំនួសនាមណា? ជាបទកម្ម ជាប្រធាន នឹងជាបទវិសេសៈរបស់នាមណាដែលបានចង្អុលបង្ហាញប្រភេទរបស់សព្វនាម ៗ

# សព្វនាម

អត្ថន័យ.– នាមដែលប្រើជំនួស ឬជាជំនួយនាមនាមដែលពោលចេញឈ្មោះមកហើយ ឬ និយាយចំពោះមុខ ដើម្បីមិនឲ្យផ្ទួនពាក្យដដែល ៗ ហៅថាសព្វនាម ។ សព្វនាមនេះទុកដើម្បីនឹងមិនឲ្យមានការប្រើពាក្យផ្ទួន ៗ ដដែល ៗ ឬដើម្បី

កាត់សេចក្ដីឲ្យលះមិនឲ្យច្រឡំដូចពាក្យថាៈ ខ្ញុំ, ឯង, គេ, នោះ, នេះ, អ្នកខ្លះ, អ្នកណា ទៀតជាដើម ។

ឧ. គេជាក្រហម អញ្ជើញពីក្រុមមួយទៅក្រុមមួយទៀត ស្រែកទៅអ្នកនេះ បង្គាប់ទៅអ្នកនោះ ស្ទុះទៅចាប់ដោយដៃលោក រួចផ្ដាកមកសង្កត់ទំនងការវិញ ។ វិម គិន

ឧ. ខ្ញុំយល់ចិត្តលោកហើយ, នារីគាត់សំដី, លោកអញ្ជើញមកជិតខ្ញុំបុះ ខ្ញុំមិនថាអ្វីទេ ។

ពាក្យថា មួយទៀត, នេះ, នោះ, ខ្ញុំ, លោក អញ្ជើញទាំងនេះជាសព្វនាម ។

សំណាក់ចំណាំ,– ត្រង់ពាក្យថា ដៃលោក និង ចិត្តលោក បណ្ឌិតវេយ្យាករណ៍ខ្លះ ពោលថា ជាសាធារណនាម បទមជ្ឈលុប មកពី ដៃរបស់លោក ចិត្តនៃលោក ។ ម្យ៉ាងទៀត តាមវេយ្យាករណ៍របស់លោក ក៉យ-ប៊ុក ពោលថាជាសាមិសម្ពន្ធគុណនាម គឺគុណនាមប្រាប់ម្ចាស់របស់ ព្រោះ

លោកកសំដែងលក្ខណៈរបស់ដៃនឹងចិត្ត សមនឹងពាក្យ បាកំង

ជា SON BRAS ដូច្នេះ ។

សព្វនាមនេះចែកជាពីរយ៉ាង គឺ៖

បុរិសសព្វនាម នឹង វិសេសនសព្វនាម

## បុរិសសព្វនាម

អត្ថន័យ .– សព្វនាមណាដែលប្រើជំនួសឈ្មោះ

មនុស្សសត្វ ឬវត្ថុដោយចំពោះរូប តែមិនបញ្ចេញឈ្មោះនោះទេ គឺ

យកពាក្យដទៃពីនោះមកប្រើជំនួសវិញដូចជា ខ្ញុំ, ឯង, វា, គេ,

អ្នកទាំងឡាយជាដើមហៅថា បុរិសសព្វនាម ។

ឧ. ចូរឯងក្រោកឡើង អញនឹងសួរឯងបន្តិច ។

វា ខ្ញុំ ឯង អញ នេះ ជាបុរិសសព្វនាម ព្រោះ

ប្រើជំនួសឈ្មោះមនុស្ស ។

## បុរិសសព្វនាមមានបីយ៉ាងគឺ

បឋមបុរិសសព្វនាម មជ្ឈិមបុរិសសព្វនាម

នឹង ឧត្តមបុរិសសព្វនាម ។

## បឋមបុរិសសព្វនាម

អត្ថន័យ.– សព្វនាមនេះសម្រាប់ប្រើជំនួសមនុស្សសត្វ ឬវត្ថុដែលពោលរួចមកហើយ គឺថា សង្កាត់នៃពាក្យខាងដើមបាន បញ្ចេញឈ្មោះម្តងរួចហើយ លុះដល់សង្កាត់ពាក្យជាបន្ទាប់ ត្រូវរក ពាក្យនាមដទៃមកជំនួសវិញ ដូចពាក្យថា គេ វា គាត់ នាង ជាដើម ។

១. ក្រោយពេលដែលជីតាខ្ញុំ អនិច្ចកម្មទៅ ជីដូនខ្ញុំគាត់ រក្សាឧបោសថសីល ឯចំណែកប្អូនខ្ញុំ វាក៏តាមគាត់ទៅវត្តដែរ ។

គាត់ វា នេះជា បឋមបុរិសសព្វនាម ។

ក្នុងភាសាយើងលោកកំណត់ឲ្យប្រើពាក្យព្រះអង្គ, លោក គេ វា, នាង តាមឋានៈខ្ពស់ទាបឬកណ្តាល ។

## មជ្ឈិមបុរិសសព្វនាម

អត្ថន័យ.– មជ្ឈិមបុរិសសព្វនាម ជាសព្វនាម សម្រាប់ប្រើជំនួសឈ្មោះបុគ្គល ដែលគេកំពុងតែនិយាយទៅ

រកក្តង់ទីចំពោះមុខ ហើយមិនបញ្ចេញចំណោះនោះឡើយ ដោយយកនាមនាមដទៃមកជំនួសវិញ ដូចពាក្យថាៈ អ្នក, នាង, ហង, ព្រះអង្គ, លោក, ជាដើម ។

១. ឯងទៅផ្ទះឥឡូវឬ? អ្នកកំពុងធ្វើអី?

ឯង, អ្នក ជា មជ្ឈិមបុរិសសព្វនាម ។

## មជ្ឈិមបុរិសសព្វនាមមានៈ

ព្រះអង្គ- ព្រះតេជព្រះគុណ, លោក, ឯង, អា, ហង, នាង, អ្នកនាង, (តាមពាក្យខ្ពស់ ទាប កណ្តាល) ។

## ឧត្តមបុរិសសព្វនាម

អត្ថន័យ.– សព្វនាមណាដែលប្រើជំនួសឈ្មោះខ្លួនឯង ដែលជាអ្នកនិយាយ គឺអ្នកនិយាយមិនបាច់បញ្ចេញឈ្មោះខ្លួន ឡើង ៗ ត្រង់ ៗ នោះទេ ដោយរកពាក្យដទៃមកជំនួសវិញដូច ពាក្យថាៈ ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំប្របាទ, ខ្ញុំបាទ, ខ្ញុំម្ចាស់, អាត្មាភាព អាត្មាអញ, អញយ៉ាងនេះជាដើម ហៅថា ឧត្តមបុរិសសព្វនាម ។

ខ. ភិក្ខុនោះសួរថា «លោកអញ្ជើញទៅណា ?»

— ទានប្រោស ខ្ញុំព្រះករុណាមកសូមអាពធនាព្រះតេជព្រះគុណទៅសម្ដែងធម៌ ។

— ទេ ! អាត្មាភាពជាប់កិច្ចទទួលនិមន្ដរបស់គេរួចហើយ ។

— ពរម្ចាស់បង ! ខ្ញុំម្ចាស់មិនព្រួយទេ សូមព្រះកស្ដាយាងទៅឲ្យមានជោគជ័យ ។

ខ្ញុំព្រះករុណា អាត្មាភាព ខ្ញុំម្ចាស់ ជាឧត្ដមបុរិសសព្វនាម ។

## ឧត្ដមបុរិសសព្វនាមទាំងឡាយគឺ:

ខ្ញុំ, ខ្ញុំបាទ ខ្ញុំឯង, អញ, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, អាត្មាភាព, អាត្មាអញ, យើង. យើងខ្ញុំ (តាមពាក្យទាប ខ្ពស់ កណ្ដាល) ។

## វិសេសនសព្វនាម

អត្ថន័យ .– វិសេសនសព្វនាម នេះគឺជាសព្វនាម សម្រាប់ប្រើជំនួសនាមនាម មានលំនាំប្រហែលគុណនាមជាបទវិសេសនៈ ដើម្បីកុំឲ្យប្រឡំសេចក្ដីក្នុងសង្កាត់ប្រយោគនីមួយ ៗ ដូចពាក្យថា៖ នោះ, នេះ, មួយទៀត, ណា, ឯទៀត, អ្នកខ្លះ ដូចម្ដេចជាដើម ។

១. អ្នកទៅណា ? ចុះអ្នកឯទៀត ? ចុះដូចម្ដេចបានជាអ្នកខ្លះនិយាយថា ខ្លះនៅឯនេះ ខ្លះនៅឯនោះ ។

ឯណា ឯទៀត ដូចម្ដេច អ្នកខ្លះ ខ្លះ ឯនេះ ឯនោះជាវិសេសនសព្វនាម ។

## វិសេសនសព្វនាមមានពីរយ៉ាងគឺ:

វិសេសសនសព្វនាមនិយម នឹង វិសេសនសព្វនាមអនិយម ។

## វិសេសនសព្ទនាមនិយម

អត្ថន័យ.— ពាក្យថា «នោះ នុ៎ះ, ហ្នឹង, នេះ, ម្នាក់ទៀត, ឯនេះ, ឯនោះ, ដែលពោលបង្អួលគួនាមនាមឲ្យប្រាកដដាច់ស្រេច នឹងដែលសម្តែងសេចក្តីទៀងទាត់ ហៅថា វិសេសនសព្ទនាមនិយម ។

## វិសេសនសព្ទនាមអនិយម

អត្ថន័យ.— សព្ទនាមណាដែលពោលជំនួសនាម ឬប្រើជាជំនួយនាមនាមមិនទៀងទាត់ហៅថា វិសេសនសព្ទនាមអនិយម ។

ដូចពាក្យថា ណា, ឯណា, ណាមួយ, ឯទៀត ដទៃ, ម្នាក់, ផ្សេង, ទៀត, ពលាខ្លះ, អ្វី, ដូចម្តេច, ខ្លះ, ទាំងមូល, ទាំងស្រុងៗ

កំណត់ចំណាំ.— វិសេសនសព្ទនាមជានិយមក្តី អនិយមក្តី មិនអាចប្រើដាច់តែម្នាក់ឯងបានទេ លុះណាតែមានពាក្យជានាមនាមឬជាបុរិសសព្ទនាម នៅជាមួយផង ទើបប្រើបានដូចគ្នានឹងគុណនាមដែរ ។

# លិង្គនិងវចនៈរបស់សព្វនាម

(គួរមើលក្នុងវិធីសម្ពន្ធនាម)

បំពោះបុរិសសព្វនាម, លិង្គនិងវចនៈត្រូវប្រព្រឹត្តទៅតាមនាមដែលខ្លួនជំនួស ។

១. ម្ដាយខ្ញុំធ្វើការនៅផ្ទះ, គាត់ដាំបាយ, បោសផ្ទះ... ។

គាត់ បុរិសសព្វនាម ជំនួសម្ដាយ ឥត្ថីលិង្គ. ឯកវចនៈ បឋមបុរស ។

ចៅសេកនឹងចៅសែមដើរទៅ បានប្រទះនឹងតាសោម គាត់សួរថា ឯងឃើញគោអញទេ?

គាត់= បុរិសសព្វនាម បុំលិង្គ ឯកវចនៈ បឋមបុរស គាត់ជំនួសឈ្មោះតាសោម ។

វា= បុរិសសព្វនាម បុំលិង្គ ពហុវចនៈ បឋមបុរសជំនួសចៅសែមនឹងចៅសេក ។

ឯង= បុរិសសព្វនាម បុំលិង្គ ពហុវចនៈ មជ្ឈិមបុរស ជំនួសចៅសេកនឹងចៅសោម ។

# មុខងាររបស់សព្វនាម

សព្វនាមមានមុខងារជា៖

ក) ប្រធានឬកម្មបទ (បុរិសសព្វនាម)

ឧ. ម្ដាយខ្ញុំត្រឡប់មកពីផ្សារវិញ ហើយឥឡូវគាត់កំពុងរៀបចំដេរអាវឲ្យខ្ញុំ ។

ខ្ញុំ (ម្ដាយខ្ញុំ)= ជាកម្មបំពេញបទរបស់ម្ដាយ ។

គាត់= ប្រធានរបស់រៀបចំ ។

ខ្ញុំ (ឲ្យខ្ញុំ) សកម្មបទរបស់ឲ្យ ។

ខ) បទវិសេសនៈ (វិសេសនសព្វនាម)

ឧ. គេជាក្រហម អញ្ជើញពីក្រុមមួយទៅក្រុមទៀត ស្រែកទៅម្នាក់នេះ បន្ទាប់ទៅម្នាក់នោះ ស្ទុះទៅចាប់ធ្វើដោយដៃលោកប្រូផាកមកសង្កត់ទំនងការវិញ ។

ទៀត= វិសេសនសព្វនាមអនិយម (ជាបទវិសេសនៈរបស់ក្រុម) ។

នេះ=វិសេសនសព្វនាមនិយម(បទវិសេសនៈរបស់អ្នក)ៗ

នោះ= វិសេសនសព្វនាម និយម (បទវិសេសនៈ របស់អ្នក) ៗ

## របៀបសម្ពន្ធ

១. ចៅប្រុកនិយាយទៅកាន់ម្ដាយវាថា៖ យប់នេះខ្ញុំមិនទៅផ្ទះទេ ព្រោះខ្ញុំត្រូវទៅតាមគ្រូពេទ្យឲ្យគាត់មកព្យាបាល ពុកទៀត ៗ

វា= បឋមបុរិសសព្វនាម បុំលិង្គ ឯកវចនៈជំនួសប្រុក ជាកម្មបំពេញបទរបស់ពាក្យម្ដាយ ៗ

នេះ= វិសេសនៈសព្វនាមនិយម បទវិសេសនៈរបស់យប់ ៗ

ខ្ញុំ= ឧត្តមបុរិសសព្វនាម បុំលិង្គ ឯកវចនៈ ជំនួសចៅប្រុក ប្រធានរបស់ទៅ ៗ

ខ្ញុំ= ឧត្តមបុរិសសព្វនាម (ដូចខ្ញុំខាងលើដែរ) ប្រធានរបស់ត្រូវទៅតាម ៗ

គាត់= បឋមបុរិសសព្វនាម ជំនួសត្រូវពេទ្យ ប៉ុលិគ្គ ឯក
វចនៈ ប្រធានរបស់មកព្យាបាល ។

## ការហាត់

១— ចូរស្រង់សព្វនាមក្នុងអត្ថបទខាងក្រោមនេះ ដោយ
ដាក់ជាពួកតាមប្រភេទរបស់វា ។

ត្រូវគោរពចំពោះកិច្ចការ .—

ការដែលជាធម្មតារបស់ក្មេងនោះ គឺការលើចលេង
សប្បាយ ។ ហេតុបានជាគេគោរព បំពោះកិច្ចនោះ ព្រោះកិច្ច
ការអាចហុចនូវមនុញ្ញផល តាមបំណងរបស់អ្នកត្រូវការជាការ
ចាំបាច់ក្នុងកិច្ចការ ។ កាលណាយើងប្រកបការងារ ក្នុងកាល
ណោះ យើងត្រូវទទួលសេចក្ដីថ្លៃថ្នូរ គឺប្រយោជន៍ដែលកើតពី
ការងារនោះ ហើយសេចក្ដីថ្លៃថ្នូរជាពិសេសនោះ គឺយើងបាន
ទុកកេរ្តិ៍ដំណែលដល់កូនចៅខាងក្រោយទៀតផង ។ ប៉ុន្តែ
កាលណាគេមិនគោរពចំពោះកិច្ចការវិញ ហេតុដែលកើតឡើង

បាននោះ គឺការមិនបានទទួលនូវលទ្ធផលប្រសើរ ហើយនរជននោះមិនអាចដុះខាត់ខ្លួនឯងឲ្យបានចំរើនក្នុងផ្លូវស្វាធ្យាយទៀតផង ដើម្បីជាគុណប្រយោជន៍នឹងសំអិតសំអាងខ្លួនឲ្យទៅជាមនុស្សមានលក្ខណៈបរិបូណ៌ ។ ហេតុដូច្នេះត្រូវអ្នកទាំងអស់គ្នាគោរពចំពោះកិច្ចការឲ្យបានម៉ត់ចត់ ។

២– ចូរសម្គាល់សព្វនាមដែលស្ថិតនៅក្នុងប្រយោគខាងក្រោមនេះ ។

ការពិភាក្សានៃសត្វសិង្ហ.– កញ្ជ្រោងដឹងខ្លួនក៏តបទាំងញ័រមាត់ញ័រកថា « ខ្ញុំឥតបានប្រព្រឹត្តឃាតកម្មនេះទេ! គឺមិនមែនរូបខ្ញុំទេ! »

+ អូ! អ្នកហ្នឹងហើយលួចខាំកូនគេ ។ គេមិនទាន់ទាំងសួរផង ឯងឆ្លើយដោះខ្លួនស្រេច អាហ្នឹងត្រូវសម្លាប់កចោលចេញ ។

៣– ការហាត់ដូចខាងលើ ។

អ្នកខ្លះរើសបានស្វាយហើយដើរទៅមុខទៅ ។ ផ្សេងពីនេះអ្នកណាដែលមិនបានទៅក៏ត្រូវបានចំណែកមួយទាំងមូលដែរ ។

# សម្ពន្ធសំខ្យាសព្ទ

ដើម្បីនឹងសម្ពន្ធសំខ្យាសព្ទ យើងត្រូវដឹង៖

១– ប្រភេទ= បកតិសំខ្យា ឬបូរណសំខ្យា (គុណនាម ឬសព្ទនាម) ។

២– ភាព= លិង្គ និងវចនៈ ។

៣– មុខងារ= បំពេញបទឬកប់ចំនួនរបស់នាមណា ?

## ប្រភេទរបស់សំខ្យាសព្ទ

អត្ថន័យ.– សព្ទសំកប់កប់ចំនួននាមនាម ឲ្យដឹងថា ប៉ុណ្ណេះ ប៉ុណ្ណោះ ហៅថាសំខ្យា សព្ទ ដូចពាក្យថា មួយ ពីរ បី ទីមួយ គម្រប់ពីរ .... ។

## សំខ្យាសព្ទបែកជាពីរយ៉ាងគឺៈ

បកតិសំខ្យា និង បូរណសំខ្យា

## បកតិសំខ្យា

អត្ថន័យ.–ដែលហៅថាបកតិសំខ្យា គឺសំខ្យាដែល កប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ, ប៉ុណ្ណោះ

ដូចរាប់ថា មួយ ពីរ បី បួន ១០០ ។ បកតិសំខ្យាចែកជាពីយ៉ាងគឺ៖

ក) ចាប់តាំងពី មួយដល់បួន ហៅថា សំខ្យាសព្វនាម ។

ខ) តាំងពីប្រាំ ឡើងទៅហៅថា សំខ្យាគុណនាម ។

## បូរណសំខ្យា

អត្ថន័យ.—សំខ្យាសំរាប់រាប់បង្គ្រប់នាមនាមជាជាន់ថ្នាក់ដូចពាក្យថា ទី ១ គម្រប់ពីរ បឋម លើកទី ៣ តតិយជាដើមហៅថាបូរណសំខ្យា ។ សំខ្យាបំពូកនេះជាគុណនាមទាំងអស់ ។

## ភាពរបស់សំខ្យាសព្វ-

លិង្គ នឹង វចនៈ របស់សំខ្យាត្រូវប្រព្រឹត្តទៅជាមួយនឹងនាមណាដែលខ្លួនបានបំពេញបទឬរាប់ចំនួនឲ្យនោះ ។

១. បណ្ដាកូនទាំងបីនេះ កូនទីមួយឆាត់ជាងគេ ។

បី= បកតិសំខ្យា គុណនាម អលិង្គ ពហុវចនៈ គុណបទរបស់កូន ។ (មើលមុខងាររបស់សំខ្យាខាងក្រោយផង)

ទីមួយ= បូរណសំខ្យា គុណនាម អលិង្គ ពហុវចនៈ គុណបទរបស់កូន ។

# មុខងាររបស់សំខ្យា

សំខ្យាសព្ទមានមុខងារជា គុណបទ ឬជាបទវិសេសន: តាមប្រភេទរបស់វា ឬបើពុំនោះសោតគ្រាន់តែជាចាំបំពេញបទ ឬភាប់ចំនួនរបស់នាមនាមក៏បាន ។

ឧ. គោពីរនេះ ស៊ីស្មៅខ្ចីក្នុងក្រោលទីបី ។

ពីរ= បកតិសំខ្យាសព្ទនាម បុំលិង្គ ពហុវចន: បទវិសេសន; របស់គោ (ឬភាប់ចំនួនឲ្យគោ) ។

ទីបី= បូរណសំខ្យា គុណនាម អលិង្គ ឯកវចន: គុណបទ របស់ក្រោល ។

# របៀបសម្ពន្ធសំខ្យាសព្ទ

ឪពុកចៅសំ ចែកប្រាក់បីរៀល ទៅកូនពៅរបស់គាត់ ប្រាំពីររៀលទៅកូនទីបី ។

បី= បកតិសំខ្យាសព្ទនាម អលិង្គ ពហុវចន: បំពេញបទឲ្យប្រាក់ ឬភាប់ចំនួនឲ្យនាមប្រាក់ ។

ទៅ= បូរណសំខ្យា គុណនាម អលិង្គ ឯកវចនៈ បំពេញបទឲ្យកូន ។

ប្រាំពីរ= បកតិសំខ្យាគុណនាម អលិង្គ ពហុវចនៈ បំពេញបទឲ្យប្រាក់ ។

ទីបី= បូរណសំខ្យាគុណនាម អលិង្គ ឯកវចនៈ បំពេញបទឲ្យកូន ។

## ការហាត់

១– ចូរសម្គាល់សំខ្យាសព្ទក្នុងប្រយោគខាងក្រោមនេះ ។

នៅក្នុងគេហដ្ឋានមួយដ៏ស្កុកស្កម្ភ គេឃើញមនុស្ស ៥ នាក់ ស្លៀកពាក់ជាឯកសណ្ឋាន ដើរដកគ្នាយ៉ាងរែករាយ ។ អ្នកទីមួយ មានវ័យចំណាស់បន្តិចនិយាយឡើងថាៈ ប្រហែលជានៅក្នុងថ្ងៃ ៥ មិថុនានេះ យើងនឹងមានទទួលរង្វាន់ធំនៃឆ្នោតជាតិហើយ ។

២– ចូរស្រង់សំខ្យាក្នុងអត្ថបទខាងក្រោមនេះ ដោយឲ្យឈ្មោះដោយឡែក ៗ ពីគ្នា ។

វិញ្ញាណប្រាំ.— វិញ្ញាណប្រាំគឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ កាយវិញ្ញាណ ១ ឃានវិញ្ញាណ ១ និងជិវ្ហាវិញ្ញាណ ១ ។ ទី ១ ចក្ខុវិញ្ញាណ គឺភ្នែកដែលអាចមើលបានវត្ថុមួយរយចំពូក ទី ២ សោតវិញ្ញាណ គឺត្រចៀកដែលស្ដាប់នូវសំឡេងមួយពាន់ មួយម៉ឺន ជាគំរប់បីនៃវិញ្ញាណ គឺកាយដែលប៉ះពាល់ត្រូវរបស់ជាអក្ខោភិនី ជំពូកបួន គឺច្រមុះសំរាប់ហិតក្លិនជាអសំខេយ្យ ទីបំផុត គឺអណ្ដាតសំរាប់ភ្លក្សរសជាតិរាប់កោដិ ។

## សម្ពន្ធកិរិយាសព្ទ

ដើម្បីនឹងសម្ពន្ធកិរិយាសព្ទយើងត្រូវដឹង៖

១– ប្រភេទ= ជាសកម្មកិរិយា ឬ អកម្មកិរិយា សយកត្តុ ឬហេតុកត្តុ ឬជាកិរិយាក្រិត (កិតកិរិយា) ។

២– កាល= បច្ចុប្បន្នកាល អតីតកាល ឬអនាគតកាល ។

៣– វចនៈ= ឯកវចនៈ ឬ ពហុវចនៈ ។

៤– បុរស= បឋមបុរស មជ្ឈិមបុរស ឬឧត្តមបុរស ។

៥– មុខងារ= តើមានពាក្យណាជាអ្នកធ្វើអំពើ (ប្រធាន)។

## ប្រភេទរបស់កិរិយា

អត្ថន័យ.— ពាក្យដែលបញ្ជាក់អំពើរបស់នាមសព្ទទាំងឡាយហៅថា កិរិយាសព្ទ ដូចពាក្យថា ស៊ី ផឹក ដេក ដើរ ជូរ ពេទ៍ ស្រែកជាដើម ។

ឧ. គ្រូដាស់តឿនសិស្សឲ្យខំរៀន ប៉ុន្តែក្មេងនោះមិនយកចិត្តទុកដាក់សោះ បើទុកជាលោកដេរភយយ៉ាងណាក៏ដោយ ក៏នៅតែភគិតលេងជាជាងរៀន ។ (ស ខាន់ឌី)

ពាក្យដាស់តឿន ខំរៀន, ទុកដាក់, ស្ដី, ដេរ, ភយ គិតលេង រៀនជា កិរិយាសព្ទ ។

កិរិយាសព្ទចែកចេញជាពីរយ៉ាងគឺ៖

សកម្មកិរិយា នឹង អកម្មកិរិយា ។

### ក) សកម្មកិរិយា

អត្ថន័យ.— កិរិយាសព្ទណាដែលត្រូវការកម្មដូចពាក្យថា ឈូស, ភយ, ទិញ, កាប់, ស៊ី, ផឹក, ជាដើម ហៅថា សកម្មកិរិយា ។

ឧ. ក្មេងនេះស៊ីបាយ, រួចហើយវាផឹកទឹក លុះរួចកិច្ចនោះ ឪពុកវាប្រើវាឲ្យឈូសឈើ គាត់វាយដែកគោល ។

ពាក្យ ស៊ី ផឹក ប្រើ ឈូស វាយនេះ ជាសកម្មកិរិយា ។

## ១) អកម្មកិរិយា

អត្ថន័យ.— កិរិយាសព្ទណាដែលមិនស្រែករកកម្មដូច ពាក្យ ថ្ងូរ ទៅ ស្រែក យំ ចាត់ជាអកម្មកិរិយា ។

ឧ. ខ្យល់បក់ សូរស័ព្ទភ្លេងលូរល្វើយ ៗ យូរ ៗ សូរមាត់ ទីទុយយំម្តង ៗ នេះហើយសូរស័ព្ទនៅវេលាយប់ ។

បក់ លូ យំ ជាអកម្មកិរិយា ។

កិរិយាស័ព្ទទាំងពីរបំពូកនេះ ចែកជាបីយ៉ាងគឺៈ

កិរិយាសយកត្តុ និង កិរិយាហេតុកត្តុ កិរិយាត្រិត

## ក) កិរិយាសយកត្តុ

អត្ថន័យ.— ដែលហៅថា កិរិយាសយកត្តុ គឺ

កិរិយាដែលធ្វើដោយខ្លួនឯង ដូចពាក្យថា ធ្វើ ស៊ី សរសេរ គូស ចង ភយជាដើម ។

ឧ. កាលណាខ្ញុំអានកាសែតរួចហើយ ខ្ញុំក៏ចាប់ដងប៉ាកាមកសរសេរគូរលេងតាមអំពើចិត្តខ្ញុំ ។

អាន ចាប់ សរសេរ គូរ ជាកិរិយាសយកត្ត ៕

កំណត់ចំណាំ.-- កិរិយាស័ព្ទទាំងប៉ុន្មានខាងលើនេះ ត្រូវចាត់ជា សកម្មកិរិយាសយកត្ត ព្រោះជាកិរិយាធ្វើអំពើដោយខ្លួនឯងហើយស្រេករកកម្មទៀត ។ នៅមានអកម្មកិរិយាសយកត្តទៀតដូចពាក្យថា យំ, ថ្ងូរ ។ល។

## ២) កិរិយាហេតុកត្ត

អត្ថន័យ,– កិរិយាសព្ទណាដែលញ៉ាំងអ្នកដទៃឲ្យធ្វើនូវអំពើអ្វីមួយ ដូចពាក្យថា បង្ហាត់ បង្រៀន ពន្យល់ ផ្ដេក ជាដើម ហៅថា កិរិយាហេតុកត្ត ។

ឧ. ម្ដាយខ្ញុំគាត់ផ្ដេកប្អូនខ្ញុំទៅលើអង្រឹង រួចគាត់បង្រៀន

ក្ពយញុំឲ្យដើរ គាត់បណ្ដើរព្រហូតដល់មុខផ្ទះ ទើបត្រឡប់មកវិញ ។ (ព.ស)

ផ្ដេក បង្រៀន បណ្ដើរ ជាកិរិយាហេតុកត្តុ, ។

សំគាល់ចំណាំ.– ឧទាហរណ៍ខាងលើនេះ ត្រូវចាត់ជាសកម្មកិរិយាហេតុកត្តុ ព្រោះជាកិរិយាស្រែករកកម្មផង ញ៉ាំងគេឲ្យធ្វើផង ។ ឯអកម្មកិរិយាមិនសូវមានពាក្យទេ ។

## គ) កិរិយាក្រិត

អត្ថន័យ.– កិរិយាដែលបែកចេញទៅជានាមសព្ទ ដូចពាក្យថា ដួញ > ដំនួញ កត់ > កំណត់ ដូចនេះ ហៅថា សកិរិយាក្រិត ។

១. យើងមិនត្រូវគិតថា យើងនឹងគុំចំពោះជន ដែលចោទយើងខុសរបៀបនោះទេ ។

គិត គុំ ចោទ ជា កិរិយាក្រិត ។

កំណត់ចំណាំ – កិរិយាណាដែលមិនក្លាយទៅជានាមកិរិយានោះមិនហៅថា កិរិយាក្រិតទេ ដូចពាក្យថា

សរសេរ សរសើរ សិក្សា អង្គុយ ស៊ី ផឹក ជាដើម ។

កំណត់ចំណាំ – មានកិរិយាម្យ៉ាងទៀត ដែលរួបរួមតាំងពីរ ២ ម៉ាត់ឡើងទៅ ដូចពាក្យថា ដើរលេង រៀនសូត្រ ស្រែកហៅយ៉ាងនេះជាដើមគួរឲ្យឈ្មោះថា សមាសកិរិយា ក៏គួរតែបើចង់ឲ្យដាច់ពីគ្នា ក្នុងពេលសម្ពន្ធនោះត្រូវឲ្យឈ្មោះ កិរិយាដែលនៅពីក្រោយហៅថា កិរិយាបន្ត ហើយមានមុខងារជាកម្មរបស់កិរិយាអាខ្យាត (មើលសេចក្ដីតទៅខាងមុខទៀត)

## កាលរបស់កិរិយា

កាលមាន ៣ គឺ:

បច្ចុប្បន្នកាល អតីតកាល និងអនាគតកាល ។

### ក) បច្ចុប្បន្នកាល

បច្ចុប្បន្នកាល គឺពេលដែលកំពុងមាននៅចំពោះមុខ

គឺពេលឥឡូវនេះ ។ គេសំគាល់បានដោយមានប្រើពាក្យថា កំពុង ឬកំពុងតែ អែបមុខកិរិយាសព្ទ ឬប្រើតែកិរិយាទទេក៏មាន

ឧ. ខ្ញុំទៅកាន់សាលារៀន ។ ឥឡូវនេះគាត់ធ្វើរទេះ ខ្ញុំកំពុងតែសរសេរ ... ។ ទៅ ធ្វើ សរសេរ បច្ចុប្បន្នកាល ។

១] អតីតកាល

កាលដែលកន្លងហួសទៅហើយ ឬកាលពីមុនមកហៅ អតីតកាល ។ កាលនេះត្រូវប្រើពាក្យ បាន ឬបានហើយ អែបមុខកិរិយាសព្ទ ។

ឧ. កាលពីឆ្នាំទៅខ្ញុំបានទៅស្រុកកំណើតម្ដង ។ ខ្ញុំបានទិញវ៉ែនតាមួយ ។ ទៅ នឹងទិញ អតីតកាល ។

៣] អនាគតកាល

កាលដែលមិនទាន់មកដល់ គឺនៅខាងមុខហៅថា អនាគតកាល ។ ប្រើជាប់ដោយពាក្យ «គង់, គង់តែ, មុខជា, ប្រហែល, ប្រហែលនឹង, នឹង ....» ។

ឧ. ថ្ងៃស្អែកនេះខ្ញុំមិនទៅសាលាទេ ។

ទៅ អនាគតកាល ។

សេចក្តីសង្ខេប.- តាមសេចក្តីសង្កេតក្នុងភាសាខ្មែរនឹង ភាសាបាលី សឹងមានកាលដូចគ្នា ដូច្នេះយើងអាចចែក កាលទាំងបីនោះជាចំណែកទៀតគឺ:

១- បច្ចុប្បន្នកាលចែកជាបីយ៉ាងគឺៈ

ក) បច្ចុប្បន្នសុទ្ធ មានអត្ថថា កំពុង, កំពុងតែ (បាលីហៅថា សុទ្ធបច្ចុប្បន្នកាល)

ខ) បច្ចុប្បន្នជិតអតីត មានអត្ថថា ទើប, ទើបនឹង (បាលីហៅថា អតីតបច្ចុប្បន្នកាល)

គ) បច្ចុប្បន្នជិតអនាគត មានអត្ថថា នឹង, រមែង, តែងតែ, គង់, គង់តែ (បាលីហៅថា អនាគតបច្ចុប្បន្នកាល)

ឧ. ឪពុកឯងកំពុងធ្វើអ្វី ? បាទ ! គាត់ទើបនឹងអញ្ជើញ មកពីផ្សារ ។ ឯងកុំធ្វើបាប ព្រោះអ្នកដែលធ្វើបាបរមែងធ្លាក់ ទៅនរក ។

ឆ្នេះ ជាសុទ្ធបច្ចុប្បន្ន ។ អំពើញ ជាអតីតបច្ចុប្បន្ន ។ ឆ្នាំក្រោយ ជាអនាគតបច្ចុប្បន្ន ។

២— អតីតកាលចែកជា ៣ យ៉ាងគឺ:

ក) អតីតកាលដែលកន្លងទៅហើយ មិនមានកំណត់ (បាលីហៅថា អបរិច្ឆន្នាតីតកាល) ។

ខ) អតីតកាលកន្លងហើយកន្លងថ្ងៃម្សិល (បាលីហៅថា ហីយត្តនាតីតកាល) ។

គ) អតីតកាលកន្លងទៅហើយកន្លងថ្ងៃនេះ ( បាលីហៅថា អជ្ជតនាតីតកាល) ។

៣— អនាគតកាលចែកជាពីរយ៉ាងគឺៈ

ក) អនាគតរបស់បច្ចុប្បន្នបាលីហៅថាបច្ចុប្បន្នានាគត)។

ខ) អនាគតរបស់អតីត (បាលីហៅថា អតីតានាគត)

នៅមានកាលមួយទៀត ដែលមិនប្រាប់ថាបច្ចុប្បន្ន អតីត ឬ អនាគត ដូចឧទាហរណ៍ថាៈ

ចូរឯងដើរចុះ ។ គប្បីឯងធ្វើទៅការនោះ ។ ការនេះអ្នកណាត្រូវធ្វើ ?

ដើរ ធ្វើ ធ្វើ ជា អនុត្តកាល ។

កំណត់ចំណាំ.— បើចង់ឲ្យកិរិយានោះៗ ទៅជាអនុត្តកាលត្រូវថែម គិរិយានុគ្រោះ, ឯកិរិយានុគ្រោះ មានដូច្នេះគឺ: ចូរ ចុះ សូម គួរតែ រមែង, តែងតែ, គប្បី, ត្រូវ ជាដើម ។

ឧ. បុណ្យនេះគឺខ្ញុំគប្បីធ្វើ ។ សូមឲ្យបានសំរេចតាមយថាផលទៅចុះ

ធ្វើ បាន ទៅ ជា អនុត្តកាល ។

## វចនៈរបស់កិរិយាសព្ទ

វចនៈរបស់កិរិយាសព្ទ ប្រព្រឹត្តទៅជាមួយប្រធាន ដែលជានាមឬ សព្វនាម ។ បើនាមនឹងសព្វនាមនោះៗ មានវចនៈយ៉ាងណា កិរិយាក៏ត្រូវមានវចនៈយ៉ាងនោះដែរ ។